
អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល







សន្និសីទជាតិលើកទី៨ ស្តីពី
បរិវត្តកម្មវិស័យអប់រំ
ប្រចាន់បទ
ពង្រីកផលជះ - ពង្រឹងប្រព័ន្ធ លើកកម្ពស់សមធម៌ និងភាពឆ្លាតវៃ
ក្នុងវិស័យអប់រំ ដើម្បីឆ្ពោះទៅកាន់ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០
១៧ - ១៨ កញ្ញា ឆ្នាំ២០២៦

គាំទ្រ និងសហការដោយ

មាតិកា

I. សេចក្តីសង្ខេប ១

II. លទ្ធផលទទួលបានពីសន្និសីទជាតិលើកទី៨ ..... ២

III. ហេតុអ្វីសន្និសីទជាតិលើកទី៨នេះមានសារៈសំខាន់? ៣

IV. គោលបំណង និងវត្ថុបំណង ៣

គោលបំណង ៣

វត្ថុបំណងជាក់លាក់ ៣

V. ការចូលរួម និងតំណាងភាគីពាក់ព័ន្ធ ៤

VI. វិធីសាស្ត្ររៀបចំសន្និសីទ៖ ពីកិច្ចសន្ទនាឆ្ពោះទៅសកម្មភាព ៥

VII. សារសំខាន់ៗពីសន្និសីទ ៦

VIII. ទស្សនៈ និងសំឡេងពីសន្និសីទ ៦

1. សារបើកកម្មវិធីរបស់ NEP ៦

2. ទស្សនៈរបស់រដ្ឋាភិបាល ៧

3. សំឡេងរបស់យុវជន ៧

4. បទបង្ហាញគន្លឹះ៖ «ស្ថានភាពនៃការប្តេជ្ញាចិត្តដែលបានសន្យា» ៧

5. ទស្សនៈក្នុងពិធីបិទ ៧

IX. វិស័យអាទិភាពទាំង៦ និងសំណើ ៨

X. តើអ្វីជាសមិទ្ធផលសម្រេចបានរបស់សន្និសីទជាតិលើកទី៨? ១៤

XI. ពីសន្និសីទឆ្ពោះទៅសកម្មភាព ១៤

XII. តួនាទីរបស់ភាគីពាក់ព័ន្ធក្នុងការអនុវត្តតាម 15

XIII. សេចក្តីសន្និដ្ឋាន ១៦

ឧបសម្ព័ន្ធ ១៧

I. សេចក្តីសង្ខេប

អង្គការភោពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) បានរៀបចំសន្និសីទជាតិលើកទី៨ ស្តីពីបរិវត្តកម្មវិស័យអប់រំ នៅថ្ងៃទី១៧-១៨ ខែកញ្ញា ឆ្នាំ២០២៦ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។ សន្និសីទនេះមានអ្នកចូលរួមចំនួន ២៧៧ នាក់ ក្នុងនោះមានស្ត្រី ១១៧ នាក់ មកពីអង្គការ/ស្ថាប័នចំនួន ១៦៦ ដែលតំណាងឱ្យស្ថាប័នរដ្ឋ រដ្ឋសភា អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារអង្គការសហប្រជាជាតិ អាជ្ញាធរអប់រំ សាកលវិទ្យាល័យ គ្រូបង្រៀន ថ្នាក់ដឹកនាំសាលារៀន អ្នកស្រាវជ្រាវ យុវជន និងតំណាងសហគមន៍ដែលប្រឈមនឹងការរើសអើង និងមិនទទួលបានសេវាគ្រប់គ្រាន់។ ដោយបន្តពីសន្និសីទជាតិលើកទី៧ ក្នុងឆ្នាំ២០២៥ សន្និសីទជាតិលើកទី៨ បានផ្តោតលើបញ្ហាប្រឈមសំខាន់មួយនៃកំណែទម្រង់អប់រំ គឺការបំលែងគោលនយោបាយ យុទ្ធសាស្ត្រ និងការប្តេជ្ញាចិត្តដែលមានស្រាប់ ឱ្យទៅជាការអនុវត្តប្រកបដោយប្រសិទ្ធភាព និងការកែលម្អដែលអាចវាស់វែងបានសម្រាប់អ្នកសិក្សា គ្រូបង្រៀន សាលារៀន និងសហគមន៍។

កម្ពុជាបានសម្រេចវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការពង្រីកលទ្ធភាពទទួលបានការអប់រំ និងការពង្រឹងប្រព័ន្ធអប់រំ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ឆ្នាំ២០២៤–២០២៨ និងកំណែទម្រង់ជាតិផ្សេងទៀត បានផ្តល់ជាមូលដ្ឋានសំខាន់សម្រាប់ការបន្តធ្វើបរិវត្តកម្មវិស័យអប់រំ។ សន្និសីទបានទទួលស្គាល់ថា ដំណាក់កាលបន្ទាប់តម្រូវឱ្យមានការពង្រឹងការអនុវត្ត គណនេយ្យភាព ការសម្រេចចិត្តផ្អែកលើភស្តុតាង ការផ្តល់ហិរញ្ញប្បទានគ្រប់គ្រាន់ និងប្រកបដោយសមធម៌ ព្រមទាំងការប្រើប្រាស់ទិន្នន័យឱ្យកាន់តែប្រសើរឡើង ដើម្បីតាមដានលទ្ធផល។

សន្និសីទបានផ្តោតលើវិស័យអាទិភាពចំនួនប្រាំមួយដែលមានទំនាក់ទំនងគ្នា៖

- ហិរញ្ញប្បទានសាលារៀនប្រកបដោយសមធម៌ និងចីរភាព
- ការធានាឱ្យកុមារគ្រប់រូបទទួលបានការរៀនសូត្រ
- បច្ចេកវិទ្យាក្នុងវិស័យអប់រំ - លក្ខខណ្ឌសម្រាប់ប្រសិទ្ធភាព និងសុវត្ថិភាព
- សាលារៀនមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ
- ឱកាសទីពីរ និងមាគ៌ាស្របគ្នា - ការចូលរៀនឡើងវិញរបស់យុវជន ការអប់រំក្រៅប្រព័ន្ធ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- លើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀនឱ្យមានគុណវុឌ្ឍិ ការគាំទ្រ និងប្រាក់បៀវត្សសមរម្យ

តាមរយៈសិក្ខាសាលាតាមប្រធានបទ អ្នកចូលរួមបានពិនិត្យ និងកែលម្អអាទិភាពតស៊ូមតិដែលបានស្នើឡើង ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យរួមមាន ភាពពាក់ព័ន្ធ ភាពអាចអនុវត្តបាន ភាពជាក់លាក់ លទ្ធផលដែលអាចវាស់វែងបាន ហិរញ្ញប្បទាន សមធម៌ និងការទទួលខុសត្រូវរបស់ស្ថាប័ន។ ដំណើរការនេះបានជួយផ្លាស់ប្តូរកិច្ចពិភាក្សាពីសេចក្តីថ្លែងការណ៍គោលនយោបាយទូលំទូលាយ ទៅជាសំណើតស៊ូមតិដែលមានភាពជាក់លាក់។ សំណើសំខាន់ៗរួមមាន ផែនទីបង្ហាញផ្លូវហិរញ្ញប្បទានវិស័យអប់រំជាក់លាក់សម្រាប់កម្ពុជាឆ្ពោះទៅរក ២,៥% នៃផលិតផលក្នុងស្រុកសរុប (GDP) នៅឆ្នាំ២០២៨ ការពង្រឹងជាបន្តបន្ទាប់នូវហិរញ្ញប្បទានសាលារៀនផ្អែកលើតម្រូវការ ការកែលម្អតម្លាភាព និងទាន់ពេលវេលានៃការបែងចែកមូលនិធិសាលារៀន ការពង្រឹងប្រព័ន្ធកំណត់អត្តសញ្ញាណ និងបញ្ជូនកុមារដែល

មានពិការភាពទៅទទួលសេវា ការពង្រីកការអប់រំពហុភាសានិងការអប់រំកុមារតូច ការពង្រឹងយន្តការព្រមានជាមុន និងការទប់ស្កាត់ការបោះបង់ការសិក្សា ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនិងបញ្ញាសិប្បនិម្មិត(AI) ប្រកបដោយសុវត្ថិភាពនិងផ្អែកលើភស្តុតាង ហេដ្ឋារចនាសម្ព័ន្ធ និងហិរញ្ញប្បទានសាលារៀន ដែលមានភាពធន់នឹងបម្រែបម្រួលអាកាសធាតុ មាគ៌ាដែលមានហិរញ្ញប្បទានសម្រាប់ការចូលរៀនឡើងវិញ និងការទទួលស្គាល់គន្លងអប់រំសម្រាប់យុវជនក្រៅសាលា ការពង្រឹងទំនាក់ទំនងរវាងការអប់រំទូទៅ ការអប់រំក្រៅប្រព័ន្ធ និងការអប់រំបណ្តុះបណ្តាល វិជ្ជាជីវៈ និងបច្ចេកទេស (TVET) ការកែលម្អប្រាក់បៀវត្សរ៍គ្រូបង្រៀន និងការចាត់តាំងគ្រូទៅតំបន់ជនបទ ការពង្រឹងការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន និងការរួមបញ្ចូលប្រព័ន្ធទិន្នន័យកម្លាំងពលកម្មអប់រំ និងសាលារៀន។

ការរួមចំណែកដ៏សំខាន់របស់សន្និសីទ គឺការរៀបចំធាតុចូលសម្រាប់របៀបវារៈតស៊ូមតិផ្អែកអប់រំឆ្នាំ២០២៦–២០២៨។ សំណើតស៊ូមតិដែលបានព្រមព្រៀង មានបំណងភ្ជាប់ជាមួយគោលដៅ ស្ថាប័នទទួលខុសត្រូវ សូចនាករ ការពិចារ ណាផ្អែកហិរញ្ញប្បទាន និងកាលបរិច្ឆេទកំណត់ច្បាស់លាស់ដើម្បីសម្រេចបាននូវលទ្ធផល។ សន្និសីទក៏បានពង្រឹងសារៈសំខាន់នៃការវាស់វែងវឌ្ឍនភាព មិនមែនត្រឹមតែថាតើគោលនយោបាយត្រូវបានអនុម័ត ឬអត់នោះទេ ប៉ុន្តែត្រូវវាស់ថាតើគោលនយោបាយទាំងនោះត្រូវបានអនុវត្ត និងការផ្លាស់ប្តូរជាវិជ្ជមានក្នុងទិដ្ឋភាពជាក់ស្តែង សម្រាប់អ្នកសិក្សា គ្រូបង្រៀន និងសាលារៀនឬយ៉ាងណា។

សេចក្តីថ្លែងការណ៍សន្និសីទរំពឹងថានឹងត្រូវបញ្ចប់ និងផ្សព្វផ្សាយជាសាធារណៈនៅខែតុលា ឆ្នាំ២០២៦។ ដំណាក់កាលបន្ទាប់នឹងផ្តោតលើការបញ្ចប់របៀបវារៈជាតិសម្រាប់ការតស៊ូមតិផ្អែកអប់រំ ការចូលរួមជាមួយស្ថាប័នទទួលខុសត្រូវ ការគាំទ្រដល់ដំណើរការគោលនយោបាយនិងថវិកា ការតាមដានការអនុវត្ត និងការពិនិត្យវឌ្ឍនភាពតាមរយៈភស្តុតាង។

ដូច្នេះ សន្និសីទជាតិលើកទី៨ មិនមែនជាចំណុចបញ្ចប់ទេ ប៉ុន្តែជាការប្រែក្លាយការប្តេជ្ញាចិត្តឲ្យទៅជាសកម្មភាព ពីសកម្មភាពទៅជាគណនេយ្យភាព និងពីបំណងនៃគោលនយោបាយទៅផលជះដែលអាចវាស់វែងបាន។

II. លទ្ធផលទទួលបានពីសន្និសីទជាតិលើកទី៨



III. ហេតុអ្វីសន្និសីទជាតិលើកទី៨នេះមានសារៈសំខាន់?

ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ កម្ពុជាបានសម្រេចវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការពង្រីកលទ្ធភាពទទួលបានការអប់រំ និងការពង្រឹងប្រព័ន្ធអប់រំ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០២៤–២០២៨ បានផ្តល់មូលដ្ឋានគោលនយោបាយសម្រាប់អភិវឌ្ឍធនធានមនុស្ស ដែលត្រូវការដើម្បីសម្រេចបានគោលបំណងអភិវឌ្ឍន៍រយៈពេលវែងរបស់កម្ពុជា។

ដូច្នេះ បញ្ហាប្រឈមដែលសន្និសីទជាតិលើកទី៨បានកំណត់ មិនមែនគ្រាន់តែជាកង្វះអាទិភាព ឬគោលនយោបាយអប់រំនោះទេ។ ផ្ទុយទៅវិញ គឺជាតម្រូវការក្នុងការពន្លឿនការអនុវត្ត និងធានាថាការប្តេជ្ញាចិត្តថ្នាក់ជាតិ អាចបំលែងទៅជាការផ្លាស់ប្តូរដែលមានអត្ថន័យនៅកម្រិតសាលារៀន និងសហគមន៍។ សន្និសីទជាតិលើកទី៨ បានពង្រីកបន្ថែមលើលទ្ធផលនៃសន្និសីទជាតិលើកទី៧ ដែលបានរៀបចំក្នុងឆ្នាំ២០២៥។ ខណៈដែលសន្និសីទជាតិលើកទី៧ បានផ្តោតលើការកំណត់អាទិភាពយុទ្ធសាស្ត្រសម្រាប់បរិវត្តកម្មវិស័យអប់រំ សន្និសីទលើកទី៨ បានផ្តោតលើដំណាក់កាលបន្ទាប់ គឺការកំណត់ថា តើអាទិភាពទាំងនេះអាចត្រូវបានអនុវត្ត ផ្តល់ហិរញ្ញប្បទាន តាមដាន និងបំលែងទៅជាលទ្ធផលដែលអាចវាស់វែងបានយ៉ាងដូចម្តេច។

សន្និសីទបានប្រព្រឹត្តទៅក្នុងដំណាក់កាលផ្លាស់ប្តូរសំខាន់មួយសម្រាប់កម្ពុជា។ ជាមួយនឹងកិច្ចខិតខំបន្តកែលម្អលទ្ធផលសិក្សា ពង្រឹងសមធម៌ និងគាំទ្រគ្រូបង្រៀន ការផ្លាស់ប្តូរនៃបរិបទហិរញ្ញប្បទានអភិវឌ្ឍន៍អន្តរជាតិ និងការរំពឹងថាកម្ពុជានឹងបញ្ចប់ស្ថានភាពជាប្រទេសអភិវឌ្ឍន៍តិចតួច បានបង្កើនសារៈសំខាន់នៃការពង្រឹងប្រព័ន្ធក្នុងស្រុក និងការកំណត់អាទិភាពវិនិយោគដែលមានភាពច្បាស់លាស់ និងចីរភាព។

ដូច្នេះ សន្និសីទបានផ្តល់វេទិកាសម្រាប់ពិនិត្យមិនត្រឹមតែថា តើកម្ពុជាគួរផ្តល់អាទិភាពលើអ្វីនោះទេ ប៉ុន្តែថែមទាំងសំណួរសំខាន់ៗដូចជា៖ តើអ្វីត្រូវផ្លាស់ប្តូរ? តើអ្នកណាទទួលខុសត្រូវ? តើត្រូវការធនធានអ្វីខ្លះ? តើត្រូវសម្រេចគោលដៅអ្វីខ្លះ? តើវឌ្ឍនភាពនឹងត្រូវវាស់វែងយ៉ាងដូចម្តេច? តើការអនុវត្តនឹងផ្តល់អត្ថប្រយោជន៍ដល់អ្នកសិក្សា និងសាលារៀនយ៉ាងដូចម្តេច?

IV. គោលបំណង និងវត្ថុបំណង

គោលបំណង

គោលបំណងសំខាន់នៃសន្និសីទជាតិលើកទី៨ គឺរួមចំណែកដល់ការរៀបចំរបៀបវារៈជាតិសម្រាប់ការតស៊ូមតិផ្នែកអប់រំ ឆ្នាំ២០២៦–២០២៨ ដោយកំណត់អាទិភាពតស៊ូមតិជាក់ស្តែង សកម្មភាពអនុវត្ត គោលដៅដែលអាចវាស់វែងបាន និងការទទួលខុសត្រូវរបស់ស្ថាប័ន។ សន្និសីទមានបំណងការប្រែក្លាយពីកិច្ចសន្ទនាទៅសកម្មភាពដែលមានភាពប្រទាក់ក្រឡាគ្នា ក្រោមការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព និងការគាំទ្រការអនុវត្តការប្តេជ្ញាចិត្តផ្នែកអប់រំដែលមានស្រាប់របស់កម្ពុជា។

វត្ថុបំណងជាក់លាក់

សន្និសីទបានផ្តោតលើវត្ថុបំណងជាក់លាក់គឺ៖

1. ធ្វើឱ្យហិរញ្ញប្បទានសាលារៀនមានសមធម៌ គ្រប់គ្រាន់ និងទាន់ពេលវេលា៖ បង្កើតមាគ៌ាដែលកាន់តែច្បាស់ឆ្ពោះទៅរកហិរញ្ញប្បទានសាលារៀនដែលគ្រប់គ្រាន់ និងប្រកបដោយសមធម៌ ដោយយកចិត្តទុកដាក់កាន់តែខ្លាំងលើភាពក្រីក្រ ភាពដាច់ស្រយាល និងភាពខុសគ្នាផ្សេងទៀតនៃតម្រូវការ។
2. ធានាឱ្យកុមារគ្រប់រូបទទួលបានការរៀនសូត្រ៖ ដោះស្រាយឧបសគ្គពាក់ព័ន្ធនឹងភាពក្រីក្រ ពិការភាព ភាសា ភូមិសាស្ត្រ ចំណាកស្រុក សុវត្ថិភាព និងការមិនរាប់បញ្ចូល ព្រមទាំងពង្រឹងកស្តុតាងដែលចាំបាច់សម្រាប់កំណត់គោលដៅការគាំទ្រ។
3. បង្កើតលក្ខខណ្ឌសម្រាប់ការប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព៖ ជំរុញការទទួលយកបច្ចេកវិទ្យាដោយផ្អែកលើកស្តុតាង ការទទួលបានដោយសមធម៌ គរុកោសល្យឌីជីថល ចំណេះដឹងអំពី AI ការការពារទិន្នន័យ និងការប្រើប្រាស់ AI ប្រកបដោយការទទួលខុសត្រូវ។
4. ពង្រឹងភាពធន់នឹងបម្រែបម្រួលអាកាសធាតុក្នុងវិស័យអប់រំ៖ កែលម្អភាពធន់នៃហេដ្ឋារចនាសម្ព័ន្ធសាលារៀន ការបន្តការសិក្សា និងហិរញ្ញប្បទានអប់រំ ដើម្បីឆ្លើយតបទៅនឹងហានិភ័យពាក់ព័ន្ធនឹងអាកាសធាតុ។
5. ពង្រឹងមាគ៌ាសិក្សាសម្រាប់ឱកាសលើកទីពីរ និងមាគ៌ាដែលមានភាពបត់បែន៖ កែលម្អការចូលរៀនឡើងវិញ ការទទួលស្គាល់គន្លងអប់រំ ការអប់រំក្រៅប្រព័ន្ធ TVET និងមាគ៌ាសិក្សាពេញមួយជីវិត សម្រាប់យុវជន និងមនុស្សពេញវ័យដែលបានផ្អាក ឬខកខានការអប់រំក្នុងប្រព័ន្ធ។
6. ពង្រឹងវិជ្ជាជីវៈគ្រូបង្រៀន៖ ភ្ជាប់ប្រាក់បៀវត្សរ៍គ្រូបង្រៀន ស្តង់ដារចូលបម្រើការងារ ការអភិវឌ្ឍវិជ្ជាជីវៈ ភាពជាអ្នកដឹកនាំ ការរីកចម្រើនក្នុងអាជីព និងការចាត់តាំងគ្រូដោយសមធម៌ ទៅក្នុងវិធីសាស្ត្រដែលមានភាពស៊ីសង្វាក់គ្នា និងមានហិរញ្ញប្បទាន។

V. ការចូលរួម និងតំណាងភាគីពាក់ព័ន្ធ

សន្និសីទបានប្រមូលផ្តុំភាគីពាក់ព័ន្ធជាច្រើនដែលចូលរួមក្នុងគោលនយោបាយអប់រំ ហិរញ្ញប្បទាន ការអនុវត្ត ការស្រាវជ្រាវ និងការតស៊ូមតិ។ អ្នកចូលរួមរួមមានតំណាងមកពី៖

- រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍដោយចីរភាព
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងមុខងារសាធារណៈ
- អាជ្ញាធរអប់រំថ្នាក់រាជធានី-ខេត្ត និងថ្នាក់ក្រោមជាតិ
- អង្គការសង្គមស៊ីវិល និងអង្គការសមាជិក NEP

- ដៃគូអភិវឌ្ឍន៍
- ទីភ្នាក់ងារអង្គការសហប្រជាជាតិ
- គ្រូបង្រៀន និងថ្នាក់ដឹកនាំសាលារៀន
- អ្នកស្រាវជ្រាវ និងអ្នកសិក្សា
- យុវជន
- តំណាងសហគមន៍ដែលប្រឈមនឹងការរើសអើង និងមិនទទួលបានសេវាគ្រប់គ្រាន់
- បណ្តាញ និងក្រុមការងារអប់រំ

ចម្រុះភាពនៃអ្នកចូលរួមបានឆ្លុះបញ្ចាំងពីលក្ខណៈ ដែលមានទំនាក់ទំនងគ្នានៃបញ្ហាដែលបានពិភាក្សា។ បរិវត្តកម្ម វិស័យអប់រំតម្រូវឱ្យមានសកម្មភាពលើហិរញ្ញប្បទាន កិច្ចគាំពារសង្គម ការអភិវឌ្ឍគ្រូបង្រៀន ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកវិទ្យា ភាពធន់នឹងអាកាសធាតុ បរិយាបន្ន និងគន្លងសិក្សា។

សន្និសីទក៏បានពង្រឹងតួនាទីរបស់ NEP ជាវេទិកាដែលភ្ជាប់សំឡេងសហគមន៍ ភស្តុតាង ទស្សនៈរបស់សង្គមស៊ីវិល និងកិច្ចសន្ទនាគោលនយោបាយថ្នាក់ជាតិ។

VI. វិធីសាស្ត្ររៀបចំសន្និសីទៈ ពីកិច្ចសន្ទនាឆ្ពោះទៅសកម្មភាព

សន្និសីទត្រូវបានរៀបចំឡើង ដើម្បីផ្លាស់ទីជាបន្តបន្ទាប់ពីបរិបទជាតិ និងភស្តុតាង ឆ្ពោះទៅរកអាទិភាពគោលនយោបាយដែលអាចអនុវត្តបាន។

- ដំណាក់កាលទី១៖ កំណត់បរិបទជាតិ - ការបើកសន្និសីទបានពិចារណាអំពីវឌ្ឍនភាពអប់រំរបស់កម្ពុជា អាទិភាពកំណែទម្រង់បច្ចុប្បន្ន និងចក្ខុវិស័យរយៈពេលវែង ឆ្នាំ២០៥០។
- ដំណាក់កាលទី២៖ នាំមកនូវទស្សនៈចម្រុះ - រដ្ឋាភិបាល សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ យុវជន អ្នកអនុវត្ត និងភាគីពាក់ព័ន្ធផ្សេងទៀត បានចែករំលែកទស្សនៈអំពីវឌ្ឍនភាពអប់រំ និងបញ្ហាប្រឈមដែលនៅសេសសល់។
- ដំណាក់កាលទី៣៖ សិក្សាវិស័យអាទិភាពទាំងប្រាំមួយ - អ្នកចូលរួមបានពិនិត្យឡើងវិញនូវ សំណើ សំខាន់ៗ ដែលបានកំណត់ក្នុងសន្និសីទជាតិលើកទី៧ ហើយសម្រេចថាតើត្រូវរក្សាទុក កែប្រែ ឬលុបចោល។ ពួកគេបាន កំណត់សូចនាករ គោលដៅ និងស្ថាប័នទទួលខុសត្រូវសំខាន់ៗ។
- ដំណាក់កាលទី៤៖ កែលម្អសំណើតស៊ូមតិ - សិក្ខាសាលាតាមប្រធានបទបានពិនិត្យ និងកែលម្អសំណើដែលបានស្នើ។
- ដំណាក់កាលទី៥៖ ប្រមូលផ្តុំអាទិភាព - អាទិភាពដែលកំពុងលេចឡើងត្រូវ បានប្រមូលផ្តុំជាធាតុចូល សម្រាប់ របៀបវារៈជាតិសម្រាប់ការតស៊ូមតិផ្នែកអប់រំ ឆ្នាំ២០២៦–២០២៨។
- ដំណាក់កាលទី៦៖ កំណត់ការតាមដាន - កិច្ចពិភាក្សាបិទសន្និសីទបានសង្កត់ធ្ងន់លើការតាមដាន គណនេយ្យភាព និងការចូលរួមជាបន្តបន្ទាប់ក្រោយពីសន្និសីទ។

VII. សារសំខាន់ៗពីសន្និសីទ

- **ពីការប្តេជ្ញាចិត្តផ្នែកគោលនយោបាយទៅការអនុវត្ត៖** សារសំខាន់មួយពីសន្និសីទ គឺកម្ពុជាបានបង្កើតគោលនយោបាយអប់រំ និងអាទិភាពកំណែទម្រង់សំខាន់ៗរួចហើយ។ បញ្ហាប្រឈមបន្ទាប់ គឺធានាថាការប្តេជ្ញាចិត្តទាំងនេះត្រូវបានអនុវត្តជាប់លាប់ និងបង្កើតលទ្ធផលដែលអាចវាស់វែងបាន ហើយនេះបញ្ជាក់តាមរយៈការវិនិយោគបន្ថែមលើវិស័យអប់រំ។
- **ពីការផ្តល់សេវាស្មើគ្នាទៅការគាំទ្រប្រកបដោយសមធម៌៖** អ្នកចូលរួមបានសង្កត់ធ្ងន់ថា ការបែងចែកធនធានស្មើគ្នា មិនសុទ្ធតែនាំទៅរកការលទ្ធផលប្រកបដោយសមធម៌នោះទេ។ អ្នកសិក្សា និងសាលារៀនដែលប្រឈមនឹងឧបសគ្គកាន់តែច្រើន អាចត្រូវការការគាំទ្របន្ថែមដើម្បីរំលាយឧបសគ្គពាក់ព័ន្ធទាំងនោះ មានដូចជាអាទិ៍ភាពក្រីក្រ ពិការភាព និន្នាការភេទ តំបន់ដាច់ស្រយាល ភាសា ចំណាកស្រុក ហានិភ័យអាកាសធាតុ និងកត្តាផ្សេងទៀត។
- **ពីសកម្មភាពទៅលទ្ធផលដែលអាចវាស់វែងបាន៖** សន្និសីទបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការវាស់វែងថាតើគោលនយោបាយ និងកម្មវិធីបានធ្វើឱ្យជីវិតរបស់អ្នកទទួលផលមានការផ្លាស់ប្តូរឬទេ ជាជាងវាស់ជោគជ័យត្រឹមតែតាមរយៈសកម្មភាព កិច្ចប្រជុំ ឬឯកសារដែលបានផលិត។
- **ពីការទទួលយកបច្ចេកវិទ្យាទៅការប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយការទទួលខុសត្រូវ៖** អ្នកចូលរួមបានទទួលស្គាល់សក្តានុពលរបស់បច្ចេកវិទ្យាឌីជីថល និង AI ខណៈពេលដែលពួកគាត់សង្កត់ធ្ងន់លើតម្រូវការកសាងសមត្ថភាពគ្រូ ភាពងាយស្រួលផ្នែកភាសា ការចូលប្រើក្រៅប្រព័ន្ធអ៊ីនធឺណិត ស្តង់ដារលទ្ធកម្ម និងការការពារទិន្នន័យ។
- **ពីការបោះបង់ការសិក្សាទៅឱកាសលើកទីពីរ៖** យុវជនដែលចាកចេញពីសាលារៀនត្រូវការគន្លងសិក្សាដែលអាចចូលដំណើរការបាន និងត្រូវបានទទួលស្គាល់ ដើម្បីត្រឡប់មកសិក្សា បន្តការអប់រំក្រៅប្រព័ន្ធ ចូលរៀន TVET និងបន្តការសិក្សា។
- **គ្រូបង្រៀនជាស្នូលនៃគុណភាពអប់រំ៖** សន្និសីទបានសង្កត់ធ្ងន់ថា ប្រាក់បៀវត្សរ៍គ្រូ ការអភិវឌ្ឍវិជ្ជាជីវៈ ការរីកចម្រើនក្នុងអាជីព ភាពជាអ្នកដឹកនាំ និងការចាត់តាំងគ្រូ ត្រូវដោះស្រាយជាសមាសធាតុដែលមានទំនាក់ទំនងគ្នានៃកំណែទម្រង់ប្រព័ន្ធអប់រំ។

VIII. ឧស្សាន: និងសំឡេងពីសន្និសីទ

1. សារបើកកម្មវិធីរបស់ NEP

NEP បានបង្ហាញតួនាទីរបស់ខ្លួនជាវេទិកាភាពជាដៃគូ ដែលភ្ជាប់អង្គការសង្គមស៊ីវិល បទពិសោធន៍នៅមូលដ្ឋាន ភស្តុតាង និងកិច្ចសន្ទនាគោលនយោបាយអប់រំ។ សារបើកបានសង្កត់ធ្ងន់លើតម្រូវការផ្លាស់ប្តូរពីអាទិភាពដែលបានកំណត់រួច ទៅជាសកម្មភាពជាក់ស្តែង ការទទួលខុសត្រូវ ធនធាន និងលទ្ធផលដែលអាចវាស់វែងបាន។

2. ទស្សនៈរបស់រដ្ឋាភិបាល

តំណាងឱ្យក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តមបណ្ឌិត អ៊ុង បូរាត បានលើកឡើងអំពីវឌ្ឍនភាពនៃកំណែទម្រង់អប់រំ និងសារៈសំខាន់នៃសកម្មភាពរួមជាបន្តបន្ទាប់។ សុន្ទរកថាបានសង្កត់ធ្ងន់លើគោលនយោបាយ និងការធ្វើផែនការផ្អែកលើភស្តុតាង សេវាអប់រំប្រកបដោយបរិយាបន្ន និងគុណភាព ការចូលរួមរបស់ភាគីពាក់ព័ន្ធ ការកែលម្អលទ្ធផលសិក្សា ការអភិវឌ្ឍគ្រូបង្រៀន ភាពជាអ្នកដឹកនាំសាលារៀន ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាឌីជីថល និងការពង្រឹងការគាំមដាន។

3. សំឡេងរបស់យុវជន

យុវជនឯកជើងឯកអប់រំ របស់អង្គការ NEP កញ្ញា ខឿន សុម៉ារី បានបង្ហាញអាទិភាពដែលបានកើតចេញពីការពិគ្រោះយោបល់ជាមួយយុវជន ស្តីពីរបៀបវារៈអប់រំ និងការរៀនសូត្រក្រោយឆ្នាំ២០៣០។ ទស្សនៈរបស់យុវជនបានលើកឡើងពីៈ ការអប់រំប្រកបដោយសមធម៌និងបរិយាបន្ន ការរួមបញ្ចូលក្រុមងាយរងគ្រោះប្រកបដោយអត្ថន័យ ការប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាព គុណភាពគ្រូបង្រៀន បំណិនជីវិត និងការណែនាំអាជីព ការរៀនសូត្រជាក់ស្តែងនិងអនុវត្ត ការអប់រំសម្រាប់ឱកាសលើកទីពីរ និងការរៀនសូត្រពេញមួយជីវិត។ សាររបស់យុវជនបានសង្កត់ធ្ងន់ថា អាទិភាពអប់រំគួរត្រូវបានគាំទ្រដោយគោលដៅច្បាស់លាស់ ហិរញ្ញប្បទានគ្រប់គ្រាន់ ទិន្នន័យដែលអាចទុកចិត្តបាន និងការគាំមដានដែលមានគណនេយ្យភាព។

4. បទបង្ហាញគន្លឹះ៖ «ស្ថានភាពនៃការប្តេជ្ញាចិត្តដែលបានសន្យា»

បទបង្ហាញគន្លឹះបានបង្ហាញដំណើររបស់កុមារ ១០០ នាក់តាមប្រព័ន្ធអប់រំ ដើម្បីបង្ហាញថាក្នុងចំណោមកុមារទាំងនោះ ៧៦,៣% បានបញ្ចប់ថ្នាក់ទី៦ ៤៨,២% បានបញ្ចប់ថ្នាក់ទី៩ និង ៣៣,៨% បានបញ្ចប់មធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១២។ ការបង្ហាញនេះបញ្ជាក់ថា យើងចាំបាច់ត្រូវដោះស្រាយបញ្ហាតាមរយៈប្រធានបទអាទិភាពទាំង៦ដែលមានទំនាក់ទំនងគ្នា។ របាយការណ៍នេះបានភ្ជាប់គោលនយោបាយអប់រំថ្នាក់ជាតិជាមួយបទពិសោធន៍របស់អ្នកសិក្សាម្នាក់ៗ និងបង្ហាញថា ហិរញ្ញប្បទាន បរិយាបន្ន បច្ចេកវិទ្យា អាកាសធាតុ គន្លងសិក្សា និងគ្រូបង្រៀន មានទំនាក់ទំនងគ្នា មិនមែនជាបញ្ហាដាច់ដោយឡែកពីគ្នានោះទេ។

5. ទស្សនៈក្នុងពិធីបិទ

វាគ្មិនកិត្តិយសបានលើកឡើងពីវឌ្ឍនភាពរបស់កម្ពុជា ខណៈដែលទទួលស្គាល់បញ្ហាប្រឈមដែល នៅតែបន្តមាន ពាក់ព័ន្ធនឹងសមធម៌ ការរៀនសូត្រមូលដ្ឋាន សមត្ថភាពគ្រូបង្រៀន ភាពធន់នឹងអាកាសធាតុ ប្រព័ន្ធទិន្ន័យ និងលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាព។ កិច្ចពិភាក្សាបានពង្រឹងសារៈសំខាន់នៃការ បំលែងអនុសាសន៍របស់សន្និសីទទៅជាសកម្មភាពជាក់ស្តែង និងការរក្សាកិច្ចសហការរវាងរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល សហគមន៍ គ្រូបង្រៀន និងថ្នាក់ដឹកនាំសាលារៀន។

IX. ទិសដៅអាទិភាពទាំង៦ និងសំណើ

សិក្ខាសាលាតាមប្រធានបទទាំង៦ គឺជាផ្នែកស្នូលនៃសន្និសីទ។ អ្នកចូលរួមបានពិនិត្យសំណើតស៊ូមតិដែលបានស្នើឡើង និងពិចារណាថា តើសំណើនីមួយៗមានភាពពាក់ព័ន្ធនឹងបញ្ហាប្រឈមផ្នែកអប់រំដែលបានកំណត់ អាចអនុវត្តបានក្នុងបរិបទស្ថាប័ន និងធនធានរបស់កម្ពុជា មានភាពជាក់លាក់និងអាចអនុវត្តបាន អាចវាស់វែងបាន មានហិរញ្ញប្បទានសមស្រប មានសមធម៌ និងបរិយាបន្ន និងភ្ជាប់ជាមួយការទទួលខុសត្រូវរបស់ស្ថាប័នច្បាស់លាស់ឬទេ។

ផ្នែកខាងក្រោមសង្ខេបបញ្ហាសំខាន់ៗ និងសំណើតស៊ូមតិដែលបានព្រមព្រៀង។

1) ប្រធានបទទី១៖ ហិរញ្ញប្បទានសាលារៀនប្រកបដោយសមធម៌ និងចីរភាព

បញ្ហា៖ អ្នកចូលរួមបានកំណត់បញ្ហាប្រឈមដែលមានទំនាក់ទំនងគ្នាចំនួនបី ក្នុងហិរញ្ញប្បទានសាលារៀន៖ មូលនិធិមិនគ្រប់គ្រាន់ ការគិតគូរមិនទាន់គ្រប់គ្រាន់អំពីភាពខុសគ្នានៃតម្រូវការ និងការយឺតយ៉ាវក្នុងការបែងចែកមូលនិធិ។ កិច្ចពិភាក្សាបានសង្កត់ធ្ងន់ថា ហិរញ្ញប្បទានសាលារៀនមិនគួរត្រូវបានវាយតម្លៃត្រឹមតែតាមចំនួនថវិកាដែលបានបែងចែកនោះទេ ប៉ុន្តែត្រូវពិនិត្យថា ថវិកាត្រូវបានបែងចែកយ៉ាងដូចម្តេច តើវាឆ្លើយតបនឹងតម្រូវការខុសៗគ្នាឬទេ និងតើការចំណាយបានរួមចំណែកដល់ការកែលម្អលទ្ធផលអប់រំឬទេ។

វិមាត្រសំខាន់ចំនួន៤ ត្រូវបានលើកឡើង៖ ទំហំ - តើមូលនិធិគ្រប់គ្រាន់ឬទេ? ចំណែក - តើមូលនិធិត្រូវបានបែងចែកយ៉ាងដូចម្តេច? ភាពឆ្លើយតបតាមតម្រូវការ - តើហិរញ្ញប្បទានឆ្លើយតបទៅនឹងតម្រូវការ ខុសៗគ្នាឬទេ? ការត្រួតពិនិត្យ - តើការចំណាយ និងលទ្ធផលមានតម្លាភាព និងគណនេយ្យភាពឬទេ? កិច្ចពិភាក្សាក៏បានលើកឡើងពីទំនាក់ទំនងរវាងហិរញ្ញប្បទានអប់រំ និងប្រាក់បៀវត្សរ៍គ្រូបង្រៀនផងដែរ។

សំណើដែលបានព្រមព្រៀង៖

- សំណើទី១៖ រៀបចំផែនទីបង្ហាញផ្លូវហិរញ្ញប្បទានជាក់លាក់សម្រាប់កម្ពុជា ឆ្ពោះទៅសម្រេច ២.៥% នៃ GDP នៅឆ្នាំ២០២៨។
- សំណើទី២៖ អនុវត្តកំណែទម្រង់សមធម៌ និងបរិយាបន្នជាដំណាក់កាល ដោយចាប់ផ្តើមពីការបន្ថែមថវិកាតាមគោលដៅក្នុងថវិកាឆ្នាំ២០២៨ ដោយផ្អែកលើសមាមាត្រប្រជាជនរស់នៅក្នុងភាពក្រីក្រ តាមប្រភេទ និងកម្រិតទាំងបីរបស់ IDPoor និងកម្រិតភាពជាប់ស្រយាល ហើយបន្តឆ្ពោះទៅរកូបមន្តផ្តល់មូលនិធិពេញលេញផ្អែកលើតម្រូវការ ក្នុងវគ្គ ESP បន្ទាប់ ដោយប្រើទិន្នន័យធាតុចូលដែលបានផ្ទៀងផ្ទាត់ ដើម្បីធានាថាការបែងចែកថវិកាត្រូវបានប្រើប្រាស់តាមគោលបំណង។
- សំណើទី៣៖ រៀបចំ និងផ្សព្វផ្សាយជាសាធារណៈនូវប្រតិទិនទៀងទាត់សម្រាប់ការបែងចែកថវិកា និងតាមដានជាសាធារណៈនូវការអនុវត្តប្រតិទិននេះតាមរយៈប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុអប់រំ (EFMS) ដើម្បីកាត់បន្ថយ និងបញ្ចប់ជាបន្តបន្ទាប់នូវការយឺតយ៉ាវយូរដែលសាលារៀនកំពុងជួបប្រទះក្នុងការទទួលបានថវិកាដែលបានបែងចែក។

- សំណើទី៤៖ ពង្រឹង និងពង្រីកផ្នែងព័ត៌មានតម្លាភាពថវិកាដែលមានស្រាប់ក្រោមការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គម (ISAF) ព្រមទាំងប័ណ្ណវាយតម្លៃរបស់ប្រជាពលរដ្ឋ Citizen Scorecards ទៅកាន់សាលាបឋមសិក្សាទូទាំងប្រទេស។
- សំណើទី៥៖ ផ្តល់ការបណ្តុះបណ្តាលគ្រប់គ្រងហិរញ្ញវត្ថុជាប្រចាំសម្រាប់នាយកសាលាគ្រប់កម្រិត និងគ្រូបង្រៀនពាក់ព័ន្ធ ដោយមានការបែងចែកថវិកាជាក់លាក់ ដើម្បីធានាការគ្រប់គ្រងថវិកាប្រកបដោយសមធម៌ និងប្រសិទ្ធភាព ជាជាងបង្កើនសម្ពាធដែលពាក់ព័ន្ធនឹងសកម្មភាពសវនកម្ម។

2) ប្រធានបទទី២ – ការធានាឱ្យកុមារគ្រប់រូបទទួលបានការរៀនសូត្រ

បញ្ហា៖ អ្នកចូលរួមបានកំណត់ភាពក្រីក្រ ការងារក្នុងគ្រួសារ ចំណាកស្រុក និងចំណាយលាក់កំបាំងពាក់ព័ន្ធនឹងការអប់រំ ជាកត្តាសំខាន់ដែលរួមចំណែកដល់ការមិនទទួលបានការអប់រំ និងការបោះបង់ការសិក្សា។ ឧបសគ្គបន្ថែមប៉ះពាល់ដល់កុមារដែលមានពិការភាព អ្នកសិក្សាជាជនជាតិដើមភាគតិច និងអ្នកសិក្សាដែលប្រើភាសាជនជាតិភាគតិច កុមារដែលរងផលប៉ះពាល់ពីចំណាកស្រុក និងកុមារដែលជួបប្រទះអំពើហិង្សា ឬការរើសអើង។ កិច្ចពិភាក្សាបានសង្កត់ធ្ងន់ថា ការសម្រេចបានលទ្ធផលសិក្សាប្រកបដោយសមធម៌ តម្រូវឱ្យដោះស្រាយទាំងឧបសគ្គសេដ្ឋកិច្ច និងធានាថាការអប់រំមានភាពពាក់ព័ន្ធ សុវត្ថិភាព និងឆ្លើយតបទៅនឹងតម្រូវការខុសៗគ្នារបស់អ្នកសិក្សា។

សំណើដែលបានព្រមព្រៀង៖

- សំណើទី១៖ ពង្រីកផែនការសកម្មភាពជាតិពហុភាសា ដោយប្រើថវិការដ្ឋ រហូតដល់ថ្នាក់ទី៤ ជាមួយសមាមាត្រ ៩០% ជាភាសាខ្មែរ និង ១០% ជាភាសាជនជាតិដើមភាគតិច។ សំណើបន្ថែម៖ ពង្រឹងសមត្ថភាព និងលើកកម្ពស់គ្រូទាំងនេះឱ្យក្លាយជាគ្រូកិច្ចសន្យារយៈពេលវែងយ៉ាងតិច ៣ ឆ្នាំ (ផ្ទេរទៅប្រធានបទទី៦)។
- សំណើទី២៖ បង្កើតវេទិកាអន្តរភ្នាក់ងារដែលផ្តល់លទ្ធភាពឱ្យសាលារៀន និងភាគីពាក់ព័ន្ធ (MoEYS, MoH និង MoSVY) ប្រើប្រាស់ប្រព័ន្ធកំណត់អត្តសញ្ញាណពិការភាពជាតិ ដោយមានឧបករណ៍កំណត់ច្បាស់លាស់ គួនាទីច្បាស់លាស់សម្រាប់បុគ្គលិកអប់រំ និងសុខាភិបាល ការធ្វើឯកទេសទិន្នន័យ និងសេវាកម្មបន្តពីការធ្វើរោគវិនិច្ឆ័យ រួមទាំងការបណ្តុះបណ្តាលអប់រំបរិយាបន្ន ក្រោមប្រធានបទទី៦ អគារដែលអាចចូលប្រើប្រាស់បាន និងផ្លូវសម្រាប់បញ្ជូនទៅសេវា។
- សំណើទី៣៖ បង្កើតប្រព័ន្ធព្រមានជាមុន ដើម្បីកែសម្រួល និងពង្រីកអាហារូបករណ៍ និងការគាំទ្រគ្រួសារដែលភ្ជាប់ជាមួយ IDPoor ដោយដោះស្រាយបញ្ហាការបោះបង់ការសិក្សា ព្រមទាំងវិធានការសម្រាប់ផ្តល់ជំនួសដល់សិស្សដែលត្រូវបានកំណត់អត្តសញ្ញាណ (ភ្ជាប់ជាមួយប្រធានបទទី៥ និងទី៦)។
- សំណើទី៤៖ បង្កើតក្របខណ្ឌសុវត្ថិភាពសាលារៀនជាសកល ស្របតាមស្តង់ដារអន្តរជាតិដែលទទួលស្គាល់ ដូចជា PSEAH ដោយមានការអនុវត្ត និងការរាយការណ៍៖ ចាត់វិធានការលើអំពើហិង្សាផ្អែកលើយេនឌ័រដែលពាក់ព័ន្ធនឹងសាលារៀន បញ្ចប់ការដាក់ទណ្ឌកម្មរាងកាយ និងការពារកុមារគ្រប់រូបពីការគំរាមកំហែង រួមទាំងការរើសអើងដោយផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។

- សំណើទី៥៖ ពង្រីកការអប់រំកុមារតូចនៅតំបន់ដែលមានភាពខ្វះខាត ដែលគម្លាតការរៀនសូត្រចាប់ផ្តើមកើតឡើងមុនថ្នាក់ទី១។

3) **ប្រធានបទទី៣ – បច្ចេកវិទ្យាក្នុងវិស័យអប់រំ - លក្ខខណ្ឌសម្រាប់ប្រសិទ្ធភាព និងសុវត្ថិភាព**

បញ្ហា៖ អ្នកចូលរួមបានទទួលស្គាល់តួនាទីកាន់តែកើនឡើងរបស់វេទិកាសិក្សាឌីជីថល ការបង្រៀនតាមអនឡាញ និង AI ក្នុងវិស័យអប់រំ។ ទន្ទឹមនឹងនេះ បច្ចេកវិទ្យាអាចពង្រឹងភាពមិនស្មើគ្នា នៅពេលអត្តិសនីឧបករណ៍ ការតភ្ជាប់អ៊ីនធឺណិត ជំនាញឌីជីថល ថ្នាល/មាតិកាដែលអាចចូលប្រើបាន និងការគាំទ្រផ្នែកភាសាមិនមានគ្រប់គ្រាន់។ ដូច្នេះ សន្និសីទបានសង្កត់ធ្ងន់ថា បច្ចេកវិទ្យាគួរត្រូវបានណែនាំដោយផ្អែកលើកស្តុតាង និងលក្ខខណ្ឌសមស្រប មិនមែនផ្អែកតែលើការទទួលយកបច្ចេកវិទ្យាប៉ុណ្ណោះទេ។

សំណើដែលបានព្រមព្រៀង៖

- សំណើទី១៖ ធ្វើការសិក្សាផ្អែកលើកស្តុតាង ដើម្បីវាយតម្លៃយ៉ាងទូលំទូលាយអំពីចំណុចខ្លាំង និងកម្រិតនៃបច្ចេកវិទ្យា/វេទិកាឌីជីថល និងមាតិកា មុនពេលពង្រីកការអនុវត្តបន្ថែមទៀត។
- សំណើទី២៖ បង្កើតគោលការណ៍សម្រាប់ការដាក់ពង្រាយបច្ចេកវិទ្យា ដែលផ្តល់អាទិភាពដល់សមធម៌ និងបរិយាបន្ន ដោយមានកញ្ចប់គាំទ្រគ្រប់ជ្រុងជ្រោយ។
- សំណើទី៣៖ បញ្ចូលគរុកោសល្យឌីជីថល និងចំណេះដឹងអំពី AI ជាម៉ូឌុលដែលទទួលស្គាល់ និងមានក្រេឌីត ក្នុងក្របខណ្ឌអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន។
- សំណើទី៤៖ បង្កើតស្តង់ដារលទ្ធកម្មសាធារណៈសម្រាប់បច្ចេកវិទ្យាអប់រំ ដែលតម្រូវឱ្យមានមុខងារជាភាសាខ្មែរ និងពហុភាសាពេញលេញ លទ្ធភាពប្រើប្រាស់ក្រៅប្រព័ន្ធអ៊ីនធឺណិត ការបង្ហាញថ្លៃដើមសរុបនៃការកាន់កាប់ និងការការពារទិន្នន័យសិស្សយ៉ាងរឹងមាំ។
- សំណើទី៥៖ អនុវត្តគោលការណ៍ណែនាំ និងក្រមប្រតិបត្តិស្តីពីការប្រើប្រាស់ ICT និង AI រួមទាំងភាពឯកជន និងការការពារទិន្នន័យ សម្រាប់គ្រូបង្រៀន និងបង្កើត/ផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពីការប្រើប្រាស់ AI ដោយសិស្ស ដែលបែងចែកតាមកម្រិតអប់រំ មុនពេលពង្រីកការរួមបញ្ចូល AI ទៅក្នុងវេទិកាអប់រំសាធារណៈបន្ថែមទៀត។

4) **ប្រធានបទទី៤ – សាលារៀនមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ**

បញ្ហា៖ ទឹកជំនន់ ព្យុះ កម្តៅខ្លាំង និងហានិភ័យអាកាសធាតុផ្សេងទៀត អាចប៉ះពាល់ដល់សុវត្ថិភាពសាលារៀន ហេដ្ឋារចនាសម្ព័ន្ធ និងការបន្តការសិក្សា។ អ្នកចូលរួមបានសង្កត់ធ្ងន់លើតម្រូវការពង្រឹងការធ្វើផែនការអប់រំដែលឆ្លើយតបនឹងអាកាសធាតុ ហិរញ្ញប្បទាន ហេដ្ឋារចនាសម្ព័ន្ធ និងការត្រៀមខ្លួនសម្រាប់គ្រាអាសន្ន។

សំណើដែលបានព្រមព្រៀង៖

- សំណើទី១៖ រៀបចំការកំណត់សម្គាល់ចំណាយអាកាសធាតុក្នុងថវិកាអប់រំដែលបានធ្វើសវនកម្មដោយប្រើប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS) សម្រាប់ការវិភាគ ពង្រឹងសមត្ថភាព MoEYS ក្នុងការរៀបចំ និងរាយការណ៍ចំណាយពាក់ព័ន្ធនឹងអាកាសធាតុ ព្រមទាំងរៀបចំឯកសារបទប្បញ្ញត្តិស្តីពីបម្រែបម្រួលអាកាសធាតុ រួមមានក្របខណ្ឌអប់រំដែលមានភាពធន់នឹងអាកាសធាតុ គ្របដណ្តប់

សាលារៀនដែលមានភាពធន់នឹងអាកាសធាតុ ការធ្វើផែនការ និងថវិកាអប់រំដែលគិតគូរពីអាកាសធាតុ និងកម្មវិធីសិក្សាអំពីអាកាសធាតុ ព្រមទាំងបែងចែក ២% នៃថវិកាអប់រំនៅឆ្នាំ២០២៨។

- សំណើទី២៖ បង្កើតប្រព័ន្ធអេកូឡូស៊ីហិរញ្ញប្បទានអាកាសធាតុ និងអប់រំ ជាដៃគូជាមួយក្រសួងបរិស្ថាន ក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍដោយចីរភាព (NCSD) ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងអភិវឌ្ឍន៍ជនបទ ដោយមានសំណើមួយជាក់ជូនមូលនិធិអាកាសធាតុអន្តរជាតិនៅឆ្នាំ ២០២៨ ដោយកសាងលើគម្រោង BRACE ដែលកំពុងអនុវត្ត។
- សំណើទី៣៖ អនុវត្តជាកាតព្វកិច្ចនូវស្តង់ដារសំណង់ដែលមានភាពធន់នឹងអាកាសធាតុ និងបរិយាបន្នសម្រាប់អគារសាលារៀនថ្មីទាំងអស់ ដោយមានស្តង់ដារជាតិរួមតែមួយ និងលក្ខណៈបច្ចេកទេសលម្អិតដែលសមស្របនឹងបរិបទអាកាសធាតុនៃតំបន់នីមួយៗ គាំទ្រដោយផែនទីហានិភ័យក្នុងប្រព័ន្ធទិន្នន័យ EMIS ដើម្បីណែនាំការកែលម្អអគារចាស់នៅតំបន់ហានិភ័យខ្ពស់ ព្រមទាំងមានកញ្ចប់ថវិកាជាក់លាក់សម្រាប់កែលម្អអគារ និងមានមេឃុំ/ចៅសង្កាត់ចូលរួមក្នុងការកំណត់ និងកំណត់អាទិភាពសាលារៀនដែលមានហានិភ័យ។
- សំណើទី៤៖ ធ្វើសវនកម្មលើការអនុវត្ត និងការធ្វើឱ្យដំណើរការនៃក្របខណ្ឌសុវត្ថិភាពសាលារៀនដែលមានស្រាប់ ដោយមានថវិកាអនុវត្ត ក្រុមការងារដែលដំណើរការបាន ការហាត់សមជាក់ស្តែងការអប់រំអំពីហានិភ័យ និងភាពធន់នឹងបម្រែបម្រួលអាកាសធាតុដែលបានបញ្ចូលក្នុងកម្មវិធីសិក្សាសមស្របតាមកម្រិតអប់រំនីមួយៗ និងពិធីការសម្រាប់ការបន្តការសិក្សា ដោយប្រើមាតិកាឌីជីថលក្រៅប្រព័ន្ធអ៊ីនធឺណិត នៅពេលសាលារៀនត្រូវបិទ។ ផ្សព្វផ្សាយគោលការណ៍ណែនាំសុវត្ថិភាពសាលារៀនទៅសហគមន៍ និងភាគីពាក់ព័ន្ធផ្សេងទៀត។
- សំណើទី៥៖ របៀបវារៈឆ្លើយតបនឹងកម្តៅ៖ កំណត់ស្តង់ដារខ្យល់ចេញចូលនិងម្លប់ លទ្ធភាពទទួលបានប្រភពទឹក ការដំឡើងប្រព័ន្ធបាញ់ទឹក សម្ភារៈសង្គ្រោះបន្ទាន់ ការគ្របដណ្តប់ដោយដើមឈើ និងភាពបត់បែននៃកាលវិភាគសិក្សា ក្នុងក្របខណ្ឌដែលការពារពេលវេលាបង្រៀន។ គោលការណ៍ណែនាំឆ្លើយតបនឹងកម្តៅរបស់សាលារៀនត្រូវបញ្ចូលក្នុងផែនការត្រៀម និងឆ្លើយតបគ្រាអាសន្នរបស់សាលារៀន (EPRP) និងរៀបចំថវិកាក្នុងផែនការហិរញ្ញវត្ថុសាលារៀន (ភ្ជាប់ជាមួយប្រធានបទទី១)។

5) ប្រធានបទទី៥ – ឱកាសទីពីរ និងមាគ៌ាស្របគ្នា – ការចូលរៀនឡើងវិញរបស់យុវជន ការអប់រំក្រៅប្រព័ន្ធ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

បញ្ហា៖ អ្នកចូលរួមបានសង្កត់ធ្ងន់ថា យុវជនដែលចាកចេញពីសាលារៀនត្រូវការឱកាសដែលអាចចូលប្រើប្រាស់បាន ដើម្បីត្រឡប់មករៀន ទទួលបានការទទួលស្គាល់ ឬបន្តការសិក្សា និងជំនាញជំនួស។ មជ្ឈមណ្ឌលសិក្សាសហគមន៍ និងការអប់រំក្រៅប្រព័ន្ធត្រូវការហិរញ្ញប្បទានប្រកបដោយចីរភាព ខណៈដែលត្រូវការពង្រឹងទំនាក់ទំនងជាមួយ TVET ដើម្បីបង្កើតគន្លងដែលមានភាពស៊ីសង្វាក់គ្នា និងត្រូវបានទទួលស្គាល់។ សន្និសីទបានសង្កត់ធ្ងន់ថា គន្លងជំនួសមិនគួរក្លាយជាផ្លូវដាច់ដោយឡែកសម្រាប់អ្នកសិក្សាដែលជួបការលំបាកនោះទេ។ ត្រូវការភាពអាចផ្លាស់ទីបានកាន់តែប្រសើរវាងការអប់រំទូទៅ ការអប់រំក្រៅប្រព័ន្ធ TVET និងការអប់រំបន្ត។

សំណើដែលបានព្រមព្រៀង៖

- សំណើទី១៖ ផ្តល់ការគាំទ្រដែលមានហិរញ្ញប្បទានសម្រាប់ការចូលរៀនឡើងវិញ និងការទទួលស្គាល់គន្លងអប់រំសម្រាប់យុវជនក្រៅសាលា ដោយមានការលើកលែងថ្លៃចំណាយដែលភ្ជាប់ជាមួយ IDPoor។
- សំណើទី២៖ បង្កើតបន្ទាត់ថវិកា និងស្តង់ដារបុគ្គលិកសម្រាប់មជ្ឈមណ្ឌលសិក្សាសហគមន៍ និងការអប់រំក្រៅប្រព័ន្ធ ដោយអ្នកសម្របសម្រួលត្រូវបានបញ្ចូលក្នុងរចនាសម្ព័ន្ធបណ្តុះបណ្តាល និងអាជីពក្រោមប្រធានបទទី៦ ហើយគ្របដណ្តប់ដោយសំណើហេដ្ឋារចនាសម្ព័ន្ធក្រោមប្រធានបទទី៣។
- សំណើទី៣៖ បង្កើតក្របខណ្ឌទទួលស្គាល់ការរៀនសូត្រពីមុនដែលអាចដំណើរការបាន ក្រោមក្របខណ្ឌគុណវុឌ្ឍិកម្ពុជា ដោយមានសមត្ថភាពវាយតម្លៃថ្នាក់ខេត្ត អ្នកវាយតម្លៃដែលបានបណ្តុះបណ្តាល និងការលើកលែងថ្លៃសេវាសម្រាប់អ្នកកាន់ប័ណ្ណ IDPoor។
- សំណើទី៤៖ បង្កើតប្រព័ន្ធដែលអាចផ្លាស់ទីបាន និងសហកម្មសិទ្ធិ/សហគ្រប់គ្រងដោយ MoEYS និង MoLVT៖ ផែនទីផ្សព្វផ្សាយជាសាធារណៈនៃគន្លងអប់រំរវាងការអប់រំមធ្យមសិក្សាទូទៅ TVET និងក្របខណ្ឌគុណវុឌ្ឍិ ដោយមានផ្លូវដែលតភ្ជាប់ និងទទួលស្គាល់រវាងគ្នា រួមទាំងគន្លងពី TVET ត្រឡប់ទៅមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា និងការវាយតម្លៃលទ្ធផលកម្មវិធី TVET ឥតគិតថ្លៃដែលផ្សព្វផ្សាយជាសាធារណៈ។
- សំណើទី៥៖ កំណត់កម្រិតអក្ខរកម្មមនុស្សពេញវ័យជាមូលដ្ឋាន តាមរយៈការពង្រឹងមជ្ឈមណ្ឌលសិក្សាសហគមន៍ ជាមូលដ្ឋានសម្រាប់ជំនាញផ្សេងទៀតដែលប្រធានបទនេះមានបំណងផ្តល់។

6) **ប្រធានបទទី៦ – លើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀនឱ្យមានគុណវុឌ្ឍិ ការគាំទ្រ និងប្រាក់បៀវត្សសមរម្យ**

បញ្ហា៖ គ្រូបង្រៀនជាស្នូលនៃគុណភាពអប់រំ។ អ្នកចូលរួមបានកំណត់បញ្ហាប្រឈមដែលមានទំនាក់ទំនងគ្នាពាក់ព័ន្ធនឹងប្រាក់បៀវត្ស៍ ការងារបន្ថែមទីពីរ គុណវុឌ្ឍិវិជ្ជាជីវៈ ការអភិវឌ្ឍវិជ្ជាជីវៈ ភាពជាអ្នកដឹកនាំ និងការចាត់តាំងគ្រូដោយសមធម៌។ សន្និសីទបានសង្កត់ធ្ងន់ថា ការអភិវឌ្ឍគ្រូបង្រៀនគួរត្រូវបានរៀបចំតាមប្រព័ន្ធជាតិដែលមានភាពស៊ីសង្វាក់គ្នា ជាជាងការបណ្តុះបណ្តាលដាច់ពីគ្នា។

សំណើដែលបានព្រមព្រៀង៖

- សំណើទី១៖ កំណត់កម្រិតប្រាក់បៀវត្ស៍អប្បបរមារបស់គ្រូ ដែលអាចលុបបំបាត់តម្រូវការរកការងារបន្ថែមទីពីរ ព្រមទាំងកញ្ចប់ចំណាយសម្រាប់ការចាត់តាំងគ្រូទៅតំបន់ជនបទ រួមមានលំនៅឋាន ប្រាក់ឧបត្ថម្ភកន្លែងស្នាក់នៅជំនួសការសាងសង់អន្តេវាសិកដ្ឋាន ប្រាក់ឧបត្ថម្ភសម្រាប់តំបន់លំបាក និងចំណូលចិត្តទីតាំងបម្រើការ ជាផ្នែកលើកទឹកចិត្តផ្នែកប្រាក់បៀវត្ស៍ និងកម្លាំងពលកម្មយ៉ាងច្បាស់លាស់ក្នុងគន្លងហិរញ្ញប្បទានរបស់ប្រធានបទទី១។ គួររួមបញ្ចូលការដំឡើងប្រាក់បៀវត្ស៍ជាប្រចាំដែលភ្ជាប់នឹងអតិផរណា និងការរីកចម្រើនក្នុងអាជីព ព្រមទាំងប្រាក់បៀវត្ស៍ដែលឆ្លុះបញ្ចាំងពីបន្ទុកការងារ និងការទទួលខុសត្រូវវិជ្ជាជីវៈរបស់គ្រូ ដើម្បីជួយកែលម្អ

ការជ្រើសរើស ការរក្សាទុក និងការចាត់តាំងគ្រូប្រកបដោយសមធម៌ ជាពិសេសនៅតំបន់ជនបទ ដែលមិនទទួលបានសេវាគ្រប់គ្រាន់។

- សំណើទី២៖ កំណែទម្រង់ការចូលបម្រើវិជ្ជាជីវៈ។ បង្កើតកម្រិតបរិញ្ញាបត្រសម្រាប់គ្រូថ្មី យុទ្ធសាស្ត្រធ្វើឱ្យវិជ្ជាជីវៈមានភាពទាក់ទាញ រួមមានការដំឡើងប្រាក់បៀវត្សរ៍មូលដ្ឋានចូលបម្រើការងារ ១០% សម្រាប់គ្រូដែលជ្រើសរើសថ្មី និងអាហារូបករណ៍សម្រាប់ការអប់រំគ្រូ ពង្រឹកសមត្ថភាពសាលាគរុកោសល្យ អនុវត្តគោលនយោបាយជ្រើសរើសមូលដ្ឋាន(ការជ្រើសរើសគ្រូផ្អែកលើសហគមន៍) ដោយបេក្ខជនគ្រូ ត្រូវបានជ្រើសរើសនៅមូលដ្ឋានតាមរយៈសម្ភាសន៍ និងការវាយតម្លៃសមត្ថភាព និងផ្តល់មូលនិធិសម្រាប់ឆ្នាំចូលបម្រើការងារ ដោយមានអ្នកណែនាំសម្រាប់គ្រូថ្មីគ្រប់រូប។
- សំណើទី៣៖ ដើម្បីលើកទឹកចិត្តគ្រូបង្រៀនឱ្យបន្តអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ បន្តការសិក្សា បង្កើនគុណវុឌ្ឍិ និងរួមចំណែកដល់ការកែលម្អគុណភាពអប់រំ សូមឱ្យ MoEYS និងស្ថាប័នអប់រំទាំងរដ្ឋ និងឯកជន ទទួលស្គាល់ និងផ្តល់ក្រេឌីតសម្រាប់វិញ្ញាបនបត្រវគ្គសិក្សាខ្លី ដែលចេញដោយស្ថាប័នបណ្តុះបណ្តាលដែលបានទទួលស្គាល់ និងមានការទទួលស្គាល់ជាផ្លូវការ។ គួរអនុវត្តតាមរយៈម៉ូឌុលដែលមានក្រេឌីត និងស្របតាមយុទ្ធសាស្ត្រជាតិមួយដែលមានហិរញ្ញប្បទាន ហើយតាមដានតាមរយៈមូលដ្ឋានទិន្នន័យរួមរបស់គ្រូ និងការបណ្តុះបណ្តាល។ ក្រេឌីតដែលប្រមូលបានតាមវិធីនេះ គួរភ្ជាប់ជាផ្លូវការជាមួយការតម្លើងឋានៈ និងប្រាក់បៀវត្សរ៍ ដើម្បីឱ្យការសិក្សាបន្ត និងការកែលម្អគុណវុឌ្ឍិ ត្រូវបានឆ្លុះបញ្ចាំងក្នុងការរីកចម្រើនអាជីពរបស់គ្រូ។
- សំណើទី៤៖ កំណែទម្រង់ការជ្រើសរើសនាយកសាលា តាមរយៈដំណើរការជ្រើសរើសដែលមានតម្លាភាព និងផ្អែកលើសមត្ថភាព ដោយមានលក្ខណៈវិនិច្ឆ័យច្បាស់លាស់ រួមមាន៖ (i) គុណវុឌ្ឍិ (សញ្ញាបត្រ ឬវិញ្ញាបនបត្រសមមូល ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង) (ii) លទ្ធផលការងារ និងការទទួលស្គាល់សមត្ថភាព (iii) សមត្ថភាពបច្ចេកទេស និង ICT និង (iv) ការប្តេជ្ញាចិត្តចំពោះការអភិវឌ្ឍវិជ្ជាជីវៈ។ គួរបំពេញបន្ថែមដោយកម្មវិធីអភិវឌ្ឍន៍នាយកសាលាដែលមានហិរញ្ញប្បទាន គោលដៅសម្រាប់ការតែងតាំងស្ត្រីក្នុងតួនាទីដឹកនាំ និងបទប្បញ្ញត្តិស្តីពីបន្ទុកការងារ ដែលនាំទៅជាបន្តបន្ទាប់កាន់តែច្រើនទៅរកភាពជាអ្នកដឹកនាំការបង្រៀន ដូចជា ការសង្កេតថ្នាក់រៀន និងសហគមន៍សិក្សាវិជ្ជាជីវៈ ជាលទ្ធផលគោលដៅ ជាជាងការកំណត់ជាចំណុចចាប់ផ្តើម។
- សំណើទី៥៖ បង្កើតសំណុំមូលដ្ឋានទិន្នន័យអប់រំដែលភ្ជាប់គ្នាមួយ (HRMIS, CPDMIS និង EMIS) ដោយមានការរាយការណ៍ជាសាធារណៈអំពីទីតាំងបម្រើការរបស់គ្រូ និងទីតាំងដែលនៅទំនេរ ដើម្បីឱ្យការបែងចែកគ្រូប្រកបដោយសមធម៌អាចត្រូវបានតាមដាន មិនមែនគ្រាន់តែអះអាងប៉ុណ្ណោះទេ។ គួរគាំទ្រដោយការតាមដានជាប្រចាំ ការពិនិត្យតាមកាលកំណត់ និងការកែលម្អប្រព័ន្ធជាបន្តបន្ទាប់ ដើម្បីធានាគុណភាពទិន្នន័យ តម្លាភាព និងការរៀបចំផែនការកម្លាំងពលកម្មប្រកបដោយប្រសិទ្ធភាព។

X. តើអ្វីជាសមិទ្ធផលសម្រេចបានរបស់សន្និសីទជាតិលើកទី៨?

សន្និសីទបានផ្តល់លទ្ធផលសំខាន់ៗដូចជា៖


- លទ្ធផលទី១ – ការផ្តោតរួមលើការអនុវត្ត៖ អ្នកចូលរួមបានអភិវឌ្ឍការយល់ដឹងរួមកាន់តែរឹងមាំថា បរិវត្តកម្មវិស័យអប់រំរបស់កម្ពុជាតម្រូវឱ្យមានមិនត្រឹមតែគោលនយោបាយល្អប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានការអនុវត្តប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងការតាមដាន។
- លទ្ធផលទី២ – វិស័យអាទិភាពដែលមានទំនាក់ទំនងគ្នាចំនួន៦៖ សន្និសីទបានផ្តល់ក្របខណ្ឌរួមសម្រាប់ដោះស្រាយហិរញ្ញប្បទាន បរិយាបន្ន បច្ចេកវិទ្យា ភាពធន់នឹងអាកាសធាតុ គន្លងសិក្សា និងវិជ្ជាជីវៈគ្រូ បង្រៀន។
- លទ្ធផលទី៣ – បំលែងអាទិភាពទូលំទូលាយទៅជាសំណើតស៊ូមតិជាក់ស្តែង៖ សិក្ខាសាលាតាមប្រធានបទបានពង្រឹងសំណើ ដោយធ្វើឱ្យវាមានភាពជាក់លាក់ អាចអនុវត្តបាន និងអាចវាស់វែងបានកាន់តែប្រសើរ។
- លទ្ធផលទី៤ – ការយកចិត្តទុកដាក់កាន់តែខ្លាំងលើសមធម៌៖ សន្និសីទបានសង្កត់ធ្ងន់ថា ប្រព័ន្ធអប់រំត្រូវឆ្លើយតបខុសៗគ្នាទៅនឹងអ្នកសិក្សា និងសាលារៀនដែលប្រឈមនឹងឧបសគ្គកាន់តែច្រើន រួមមានភាពក្រីក្រ ពិការភាព ភូមិសាស្ត្រ ភាសា ចំណាកស្រុក សុវត្ថិភាព និងការផ្តោកការសិក្សា។
- លទ្ធផលទី៥ – ការតភ្ជាប់កាន់តែរឹងមាំរវាងកស្តុតាង និងការតស៊ូមតិ៖ កស្តុតាង និងបទពិសោធន៍ ដែលបានចែករំលែកដោយភាគីពាក់ព័ន្ធ ត្រូវបានប្រើប្រាស់ដើម្បីផ្តល់ព័ត៌មានដល់សំណើ នៅទូទាំងប្រធានបទទាំង៦។
- លទ្ធផលទី៦ – មូលដ្ឋានសម្រាប់របៀបវារៈជាតិសម្រាប់ការតស៊ូមតិផ្នែកអប់រំ។ សំណើដែលបានព្រមព្រៀងផ្តល់ជាតុចូលសំខាន់ៗសម្រាប់របៀបវារៈជាតិសម្រាប់ការតស៊ូមតិផ្នែកអប់រំ ឆ្នាំ២០២៦–២០២៨ រួមមានគោលដៅដែលបានស្នើ ការទទួលខុសត្រូវ សូចនាករ ការពិចារណាផ្នែកហិរញ្ញប្បទាន និងកាលកំណត់។

XI. ពីសន្និសីទឆ្ពោះទៅសកម្មភាព

សន្និសីទគួរត្រូវបានយល់ថាជាចំណុចចាប់ផ្តើមនៃដំណើរការតស៊ូមតិ និងការអនុវត្តដែលមានរយៈពេលវែង។ វដ្តនៃការតាមដានដែលបានស្នើឡើង៖

ពេលវេលា	សកម្មភាព	លទ្ធផលរំពឹងទុក
តុលា ២០២៦	បញ្ចប់ការរៀបចំសេចក្តីថ្លែងការណ៍សន្និសីទ	សេចក្តីថ្លែងការណ៍សន្និសីទត្រូវបានផ្សព្វផ្សាយ
តុលា – វិច្ឆិកា ២០២៦	បញ្ចប់ការរៀបចំរបៀបវារៈតស៊ូមតិផ្នែកអប់រំថ្នាក់ជាតិ	របៀបវារៈតស៊ូមតិផ្នែកអប់រំឆ្នាំ ២០២៦-២០២៨
ចុងឆ្នាំ២០២៦	ចូលរួមជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ច	ការចូលរួមក្នុងដំណើរការគោលនយោបាយ និងថវិកា
២០២៦-២០២៧	តាមដានវឌ្ឍនភាពនៃសំណើតស៊ូមតិដែលមានអាទិភាព	ការតាមដាន និងប្រមូលភស្តុតាង
២០២៧	បន្តការតស៊ូមតិលើគោលនយោបាយ និងថវិកា	ការឆ្លើយតប និងការអនុវត្តរបស់ស្ថាប័នពាក់ព័ន្ធ
ចុងឆ្នាំ២០២៧	រៀបចំការពិនិត្យឡើងវិញប្រចាំឆ្នាំ	ការវាយតម្លៃវឌ្ឍនភាព និងការកែសម្រួលផែនការអនុវត្ត

២០២៨	ពិនិត្យវឌ្ឍនភាពនៃការអនុវត្តធៀបនឹងអាទិភាព សម្រាប់ឆ្នាំ ២០២៦-២០២៨	កសុតាងបង្ហាញពីការអនុវត្ត និងលទ្ធផលដែលសម្រេចបាន



XII. តួនាទីរបស់ភាគីពាក់ព័ន្ធក្នុងការអនុវត្តតាម

បរិវត្តកម្មវិស័យអប់រំតម្រូវឱ្យមានសកម្មភាពដែលមានការសម្របសម្រួល។

រាជរដ្ឋាភិបាល	**រដ្ឋសភាជាតិ**	**អង្គការសង្គមស៊ីវិល និងសមាជិក NEP**	**ដៃគូអភិវឌ្ឍន៍**	**សាលារៀន និងគ្រូបង្រៀន**	**យុវជន និងសហគមន៍**
ដឹកនាំការអនុវត្តគោលនយោបាយ ហិរញ្ញប្បទាន បទប្បញ្ញត្តិ ប្រព័ន្ធទិន្នន័យ និងការផ្តល់សេវា	គាំទ្រការត្រួតពិនិត្យ កិច្ចសន្ទនាគោលនយោបាយ និងគណនេយ្យភាពចំពោះការប្តេជ្ញាចិត្តផ្នែកអប់រំ	នាំយកកសុតាងពីសហគមន៍ តាមដានការអនុវត្ត គាំទ្រកិច្ចសន្ទនា គោលនយោបាយ និងលើកកម្ពស់សំឡេងរបស់ក្រុម ដែលមិនទទួលបានសេវាគ្រប់គ្រាន់	គាំទ្រការបង្កើតកសុតាង ជំនួយបច្ចេកទេស នវានុវត្តន៍ និងហិរញ្ញប្បទានប្រកបដោយចីរភាព ព្រមទាំងពង្រឹងប្រព័ន្ធជាតិ	បំលែងកំណែទម្រង់ទៅជាការអនុវត្ត និងផ្តល់កសុតាងអំពីបញ្ហាប្រឈម និងលទ្ធផលនៃការអនុវត្ត	ចូលរួមប្រកបដោយអត្ថន័យក្នុងកិច្ចសន្ទនាគោលនយោបាយ អប់រំ ដំណើរការតាមដាន និងគណនេយ្យភាព

XIII. សេចក្តីសន្និដ្ឋាន

សន្និសីទជាតិលើកទី៨ ស្តីពីបរិវត្តកម្មវិស័យអប់រំ បានផ្តល់វេទិកាថ្នាក់ជាតិសម្រាប់ភាគីពាក់ព័ន្ធ ពិនិត្យវឌ្ឍនភាពអប់រំរបស់កម្ពុជា កំណត់បញ្ហាប្រឈមដែលនៅតែបន្តមានក្នុងការអនុវត្ត និងអភិវឌ្ឍអាទិភាពតស៊ូមតិដែលអាចអនុវត្តបាន។ ដោយកសាងលើសន្និសីទជាតិទី៧ សន្និសីទជាតិលើកទី៨ បានផ្លាស់ប្តូរកិច្ចពិភាក្សាពីការកំណត់ថាតើគួរមានអាទិភាពអប់រំអ្វីខ្លះ ទៅរកការពិភាក្សាថាតើការប្តេជ្ញាចិត្តដែលមានស្រាប់អាចត្រូវបានអនុវត្ត ផ្តល់ហិរញ្ញប្បទាន តាមដាន និងបំលែងទៅជាការកែលម្អដែលអាចវាស់វែងបានសម្រាប់អ្នកសិក្សា គ្រូបង្រៀន សាលារៀន និងសហគមន៍យ៉ាងដូចម្តេច។

វិស័យអាទិភាពទាំង៦ បានបង្ហាញថា បរិវត្តកម្មវិស័យអប់រំ មានទំនាក់ទំនងគ្នា។ ហិរញ្ញប្បទានប៉ះពាល់ដល់សមត្ថភាពរបស់សាលារៀន ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកសិក្សា។ បរិយាបន្នពឹងផ្អែកលើទិន្នន័យ សេវា និងធនធាន។ បច្ចេកវិទ្យាត្រូវការហេដ្ឋារចនាសម្ព័ន្ធ សមត្ថភាពគ្រូ និងវិធានការការពារ។ ភាពធន់នឹងអាកាសធាតុត្រូវការការវិនិយោគ និងការធ្វើផែនការ។ មាគ៌ាអប់រំសម្រាប់ឱកាសលើកទីពីរ ត្រូវការ ការសម្របសម្រួលរវាងការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និង TVET។ គុណភាពគ្រូបង្រៀនអាស្រ័យលើប្រាក់បៀវត្សរ៍ ការអភិវឌ្ឍវិជ្ជាជីវៈ ភាពជាអ្នកដឹកនាំ និងការចាត់តាំងប្រកបដោយសមធម៌។

ការរួមចំណែកសំខាន់មួយរបស់សន្និសីទ គឺការបំលែងកង្វល់គោលនយោបាយទូលំទូលាយទៅជាសំណើតស៊ូមតិដែលមានភាពជាក់លាក់ជាងមុន។ សកម្មភាពដែលបានស្នើរួមមានគោលដៅ ស្តាប់នទទួលខុសត្រូវ សូចនាករ ការពិចារណាផ្នែកហិរញ្ញប្បទាន និងកាលកំណត់ ដែលផ្តល់មូលដ្ឋានកាន់តែរឹងមាំសម្រាប់កិច្ចសន្ទនាគោលនយោបាយ និងគណនេយ្យភាពជាបន្តបន្ទាប់។ សន្និសីទក៏បានពង្រឹងថា សមធម៌ត្រូវតែបន្តស្ថិតនៅចំណុចកណ្តាលនៃបរិវត្តកម្មវិស័យអប់រំ។ អ្នកសិក្សាដែលប្រឈមនឹងឧបសគ្គពាក់ព័ន្ធនឹងភាពក្រីក្រ ពិការភាព ភូមិសាស្ត្រ ភាសា ចំណាកស្រុក សុវត្ថិភាព ឬការ ផ្អាកការសិក្សា អាចត្រូវការការគាំទ្របន្ថែម និងផ្តោតគោលដៅ ដើម្បីអាចចូលរួម និងទទួលបានជោគជ័យក្នុង ការសិក្សា។

ដូច្នេះ ដំណាក់កាលបន្ទាប់មានសារៈសំខាន់ខ្លាំង។ សេចក្តីថ្លែងការណ៍សន្និសីទ និងរបៀបវារៈជាតិសម្រាប់ការតស៊ូមតិផ្នែកអប់រំ ឆ្នាំ២០២៦–២០២៨ គួរផ្តល់មូលដ្ឋានសម្រាប់ការចូលរួមជាបន្តជាមួយស្តាប់នទទួលខុសត្រូវ ដំណើរការគោលនយោបាយ និងថវិកា និងការតាមដានការអនុវត្ត។

ជាចុងក្រោយ តម្លៃរបស់សន្និសីទជាតិលើកទី៨ មិនគួរត្រូវបានវាយតម្លៃតាមចំនួនអនុសាសន៍ដែលបានផលិតឡើងនោះទេ ប៉ុន្តែត្រូវវាយតម្លៃតាមថា តើអនុសាសន៍ទាំងនោះបានរួមចំណែកដល់ ឱកាស និងលទ្ធផលសិក្សាកាន់តែប្រសើរ លទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌កាន់តែខ្ពស់ ការគាំទ្រគ្រូបង្រៀនកាន់តែរឹងមាំ សាលារៀនដែលមានសុវត្ថិភាព និងភាពធន់នឹងអាកាសធាតុកាន់តែប្រសើរ ការប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយការទទួលខុសត្រូវ និងបរិយាបន្ន ឱកាសសម្រាប់ឱកាសលើកទីពីរ និងការរៀនសូត្រពេញមួយជីវិតកាន់តែរឹងមាំ និងគណនេយ្យភាពកាន់តែខ្ពស់ចំពោះការប្តេជ្ញាចិត្តផ្នែកអប់រំ។

ដូច្នេះ សន្និសីទជាតិលើកទី៨ គឺជាចំណុចផ្លាស់ប្តូរពីការប្តេជ្ញាចិត្តទៅសកម្មភាព ពីសកម្មភាពទៅគណនេយ្យភាព និងពីបំណងគោលនយោបាយទៅផលប៉ះពាល់ដែលអាចវាស់វែងបាន។

ឧបសម្ព័ន្ធ

- ឯកសារទស្សនទាននៃសន្និសីទ
- របៀបវារៈសន្និសីទ
- សុន្ទរកថា/សាររបស់វាគ្មិនសំខាន់ៗ៖
  - សុន្ទរកថាស្វាគមន៍៖ កញ្ញា ទី រ៉ូហ្សាណែត ប្រធានក្រុមប្រឹក្សាភិបាលអង្គការ NEP
  - សុន្ទរកថាបើក៖ ឯកឧត្តមបណ្ឌិត អ៊ុង បូរាត រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា
  - សំឡេងយុវជន៖ កញ្ញា ខឿន សុម៉ារី យុវជនដើរឯកអប់រំអង្គការ NEP
  - បទបង្ហាញគន្លឹះ៖ «**ស្ថានភាពនៃការប្តេជ្ញា**ចិត្តដែលបានសន្យា» ដោយលោកបណ្ឌិត សឿង សុផា នាយកនាយកដ្ឋានអប់រំទូទៅ PSE
  - សុន្ទរកថាក្នុងកម្មវិធីបិទ៖ លោកបណ្ឌិត Anirban Chatterjee អនុប្រធានតំណាងអង្គការ UNICEF ប្រចាំកម្ពុជា និងប្រធានក្រុមការងារវិស័យអប់រំ
  - សេចក្តីថ្លែងការណ៍សន្និសីទ៖ កញ្ញា ទី រ៉ូហ្សាណែត ប្រធានក្រុមប្រឹក្សាភិបាលអង្គការ NEP
  - សុន្ទរកថាបិទ លោកជំទាវ ខេង សំវ៉ាដា អនុប្រធាន/ប្រធានស្តីទីគណៈកម្មការទី៧ នៃរដ្ឋសភា
- រូបថតសន្និសីទ

សូមស្កេន QR Code ដើម្បីទាញយកឯកសារឧបសម្ព័ន្ធ

អង្គការភាពជាដៃគូអប់រំ
នៃអង្គការក្រៅរដ្ឋាភិបាល | NGO Education Partnership

www.nepcambodia.org
info@nepcambodia.org
+855 12 224 775
https://t.me/NEPComms
ផ្ទះលេខ ១១០ ផ្លូវលេខ ១២BT សង្កាត់បឹងទំពន់
ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ